01642961

D363/1.1.8

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/អជសអ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 02 / 2020
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អជសអ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើដល់អង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីទទួលបានសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនៃសំណុំរឿង ០០៤/០២ (អោ អាន)

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. Hollis
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Martin KAROPKIN
ចៅក្រម យូរ ឧត្តរា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

**សហមេធាវី អោ អាន**
លោក មុំ លុដ្ឋ
លោក Richard ROGERS
លោក Göran SLUITER

# I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ស្នើសុំដោយគោរពថា អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ឲ្យស្នើទៅកាន់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ឲ្យ ចាត់វាល់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីឲ្យមានការបញ្ជូនជាបន្ទាន់នូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1] ក្នុងកម្រិតដែលថា វិធានការបន្ថែមទៀតត្រូវឲ្យមានដើម្បីឲ្យ អ.ជ.ស.ដ ចូលពិនិត្យមើលឯកសារសាធារណៈនេះ និងប្រសិនបើ អ.ជ.ស.ដ ពិចារណាថា ត្រូវការឲ្យមានការបញ្ជូនតាមបែបរដ្ឋបាល នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈនេះ) និងសំណុំរឿងសេសសល់ក្នុងរឿងក្តី ០០៤/២ ("រឿងក្តី") នេះ ទៅកាន់ អ.ជ.ស.ដ ។ម្យ៉ាងវិញទៀត ប្រសិនបើ អ.ប.ជ មិនបានចាត់វិធានការរដ្ឋបាលចាំបាច់ ដើម្បីនាំឲ្យមានការបញ្ជូនរឿងក្តីនេះមកកាន់ អ.ជ.ស.ដ ឲ្យបានឆាប់បំផុតដែលអាចធ្វើបាន ក្រោយពេលដែលទទួលបានសំណើរបស់ អ.ជ.ស.ដ ទេនោះ ស.ព.អ ស្នើសុំឲ្យ អ.ជ.ស.ដ បង្គាប់ឲ្យការិយាល័យរដ្ឋបាលផ្តល់ការអនុញ្ញាតឲ្យខ្លួនចូលពិនិត្យមើលរឿងក្តីនេះជាបន្ទាន់។ ជាងនេះទៀត ស.ព.អ ស្នើសុំថា អ.ជ.ស.ដ ផ្តល់ឲ្យផ្នែកគ្រប់គ្រងតុលាការ ("CMS") នូវលេខសំណុំរឿងសម្រាប់រឿងក្តីនេះ និងសុំបញ្ជាក់ឡើងវិញអំពីសំណើរបស់ខ្លួនដែលថា ស្នើសុំឲ្យ អ.ជ.ស.ដ រៀបចំកាលវិភាគកិច្ចប្រជុំរៀបចំសវនាការ[2]។

2. ស.ព.អ ធ្វើសំណើនេះដើម្បីដាក់ឲ្យដំណើរការ "គោលជំហរស្វ័ប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់"[3] ដែល អ.ប.ជ បានសម្រេចជាឯកច្ឆ័ន្ទថា "ជាមុខងារសំខាន់នៃក្របខណ្ឌគតិយុត្តិ អ.វ.ត.ក"[4] ដែលរឿងក្តីនេះត្រូវបន្តទៅជំនុំជម្រះ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក[5]

---

[1] ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[2] *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងវិធាន ៨០ និងបើកកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ("សំណើរបស់ ស.ព.អ សុំបើកកិច្ចប្រជុំរៀបចំសវនាការ")។

[3] សំណុំរឿង០០៤/២ ឯកសារ **D359/24** & **D360/33**, សេចក្តីពិចារណារបស់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណា"), កថាខណ្ឌ ១១២។

[4] សំណុំរឿង០០៤/២ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់ អ.ប.ជ កថាខណ្ឌ ១០៦។

[5] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៥(៤), ៧(៤)។

ច្បាប់ អ.វ.ត.ក[6] វិធានផ្ទៃក្នុង ("វិធាន")[7]។ គោលជំហរស្វ័យប្រវត្តិ ដែលថារឿងក្តីនេះត្រូវបន្តទៅជំនុំជម្រះ ត្រូវតែអនុវត្ត ដោយហេតុថា អ.ប.ជ ខកខានមិនអាចរកសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនរូប ក្នុងចំណោមចៅក្រមទាំងប្រាំរូប ដើម្បីបដិសេធដីការបញ្ជូនរឿងទៅ ជំនុំជម្រះ។ សំណើរនេះក៏ត្រូវបានធ្វើឡើងដើម្បីធានាថា អោ អាន ត្រូវបានជំនុំជម្រះយ៉ាងឆាប់រហ័សដូចដែលតម្រូវដោយមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក។

3. ក្នុងកម្រិតដែលថាដំណាក់កាលជាផ្លូវការនេះត្រូវបានតម្រូវ ស.ព.អ យល់ឃើញថា អ.ជ.ស.ដ ត្រូវធានាឲ្យមានវិធានការកែតម្រូវភ្លាមៗ ដើម្បីធានាឲ្យមានការបញ្ជូនដ៏ឆាប់រហ័សនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងសេសសល់ ទៅកាន់ អ.ជ.ស.ដ ដើម្បីតម្កល់ សច្ចភាព និងតម្លាភាពផ្លូវច្បាប់ ដែលត្រូវបានផ្តល់ជូនដោយគោលជំហរស្វ័យប្រវត្តិ និងដែលត្រូវបានតម្រូវដោយវិធាន ២១(១)។

4. សុំសន្និដ្ឋានដោយគោរពថា ផលប៉ះពាល់នៃការខកខានជាបន្តទៀតមិនបន្តដំណើរការរឿងក្តីនេះទៅជំនុំជម្រះ នឹងជួយច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង អោ អាន។ លទ្ធផលបែបនេះនឹងផ្ទុយទៅនឹងលក្ខខណ្ឌតម្រូវនានានៃគោលជំហរស្វ័យប្រវត្តិ បដិសេធសិទ្ធិរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានយុត្តិធម៌ ធ្វើឲ្យអន្តរាយដល់សេចក្តីថ្លៃថ្នូរនៃដំណើរការរបស់ អ.វ.ត.ក និង និងបង្អាក់សណ្តាប់ធ្នាប់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនៅក្នុងរឿងក្តីនេះ។

## II. ប្រវត្តិនីតិវិធី

5. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានជូនដំណឹងអំពីសេចក្តីពិចារណាជាសាធារណៈរបស់ខ្លួនក្នុងសំណុំរឿងនេះ[8]។ អ.ប.ជ ខកខានមិនបានឈានទៅដល់សេចក្តីសម្រេចមួយដែលមានសំឡេង

---

[6] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានវិសោធនកម្មនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/២០០៦) ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ថ្មី។

[7] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង" ឬ "វិធាន") វិធាន ៧៧(១៣)(ខ), ៧៩(១)។

[8] បញ្ជីចម្លងជូនរួមមានឈ្មោះចៅក្រម អ.ជ.ស.ដ ពីររូប គឺចៅក្រម Claudia Fenz និងចៅក្រម Martin Karopkin ក៏ដូចជាក្រឡាបញ្ជី អ.ជ.ស.ដ និងមន្ត្រីច្បាប់ លឹម ស៊ុយហុង។ *ផ្ទុយពី* អ៊ីម៉ែលមានចំណងជើងថា "ព័ត៌មាន" ដែលបញ្ជូនដោយ លឹម ស៊ុយហុង ធ្វើតាងនាមឲ្យ អ.ជ.ស.ដ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១:៤៨ រសៀល ដែលបានថ្លែងថា៖ "អង្គជំនុំជម្រះបានសុំឲ្យខ្ញុំជូនដំណឹងអ្នកដូចខាងក្រោមនេះ៖ អង្គជំនុំជម្រះបានដឹងអំពីសេចក្តីពិចារណាដែលមានជាសាធារណៈ ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានចេញដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ និង

លើសលុប (សំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូបក្នុងចំណោមចៅក្រមប្រាំរូប) ដើម្បីទទួលបានសំឡេងភាគច្រើនដែលតម្រូវ ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈនេះ។

6. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្របតាមវិធាន ៣៩(៤), ៧៧(១៣)(ខ), ៨០(១) និង ៧៩ ស.ព.អ បានដាក់ជាសំណៅរឹងនូវសំណើមួយទៅកាន់ អ.ជ.ស.ដ ស្នើសុំការពន្យារពេលដាក់ឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន និងបានស្នើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការ[9]។ ស.ព.អ ដឹងថាការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់ អ.ជ.ស.ដ។

7. នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស.ព.អ បានទទួល "សំណើរបស់ អោ អាន" ស្នើសុំឲ្យ អ.ជ.ស.ដ បញ្ជាក់ថាខ្លួនមិនត្រូវបានប្ដឹងឲ្យទទួលយករឿងក្ដី០០៤/២ ដោយត្រឹមត្រូវតាមច្បាប់នោះទេ ឬជាជម្រើសម្យ៉ាងទៀតថា អ.ជ.ស.ដ ផ្ដល់ការណែនាំចំពោះការដាក់អញ្ញត្រកម្ម និងអនុញ្ញាតផ្ដល់ឲ្យ អោ អាន នូវពេលវេលាគ្រប់គ្រាន់ (យ៉ាងហោចណាស់ ៦០ថ្ងៃ) ដើម្បីដាក់ការជំទាស់របស់គាត់[10]។ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរនេះជាសំណៅរឹងនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២០[11]។ ស.ព.អ ដឹងថាការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់ អ.ជ.ស.ដ។

---

ឯកសារ ដែលអ្នកបានបញ្ជូនមកកាន់អង្គជំនុំជម្រះសាលាដំបូង។ ទោះជាយ៉ាងណា សេចក្ដីពិចារណាទាំងអស់ នេះមិនទាន់ បានជូនដំណឹងមកកាន់អង្គជំនុំជម្រះនៅឡើយទេមកទល់ពេលនេះ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងក៏មិនត្រូវបានបញ្ជូនមកនៅឡើយដែរ"។ អ៊ីម៉ែលនេះត្រូវបានផ្ញើចេញទៅកាន់សហព្រះរាជអាជ្ញា សហមេធាវីរបស់ អោ អាន ចៅក្រមនៃអង្គបុរេជំនុំជម្រះ និងប្រធាន និងអនុប្រធាននៃការិយាល័យរដ្ឋបាល។ (អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០, ១:៤៨ រសៀល)។

[9] *សូមមើល* សំណើរបស់ ស.ព.អ ស សុំបើកកិច្ចប្រជុំរៀបចំសវនាការ ដែលត្រូវបានបញ្ជូនជាសំណៅរឹងទៅកាន់ក្រឡាបញ្ជី អ.ជ.ស.ដ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។ *សូមមើលផងដែរ* អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ២០២០ វេលាម៉ោង ១:៤៨ ល្ងាច ដោយបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់ អ.ជ.ស.ដ។ មិនមានលេខឯកសារសំណុំរឿងត្រូវបានកំណត់លើសំណើរបស់ ស.ព.អ នៅឡើយទេមកទល់ពេលនេះ។

[10] *សូមមើល* សារអេឡិចត្រូនិកផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពី Göran Sluiter នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៣:៣៣ ល្ងាច។ សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្ដីត្រូវបានចម្លងជូន តែដើមបណ្ដឹងរដ្ឋប្បវេណីមិនទទួលបានទេ។ ភ្ជាប់ទៅនឹងអ៊ីម៉ែលនោះគឺជាលិខិតចេញពីសហមេធាវីការពារក្ដីផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៩។ សូមមើលផងដែរ អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១:៤៨ ល្ងាច។ មិនមានលេខឯកសារសំណុំរឿងត្រូវបានកំណត់លើសំណើរបស់ អោ អាន នោះទេ មកទល់ពេលនេះ។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ទាក់ទងនឹងការទទួលសំណុំរឿង០០៤/២ ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ២០២០។ *សូមមើលផងដែរ* អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង

8. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដោយមិនបានទទួលការបង្គាប់ណាមួយពី អ.ជ.ស.ដ ទាក់ទងនឹងសំណើសុំពន្យាពេលដាក់បញ្ជីរបស់ខ្លួន ស.ព.អ បានដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួនអនុលោមតាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុងជាសំណៅរឹង ស្របតាមកាលបរិច្ឆេទនៃសំណើសុំពន្យាពេល[12]។ ស.ព.អ ដឹងថាការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់ អ.ជ.ស.ដ។

9. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ស.ព.អ បានទទួលសារណាតាមរយៈសារឡិចត្រូនិកមួយ ដែលមានចំណងជើងថា "សេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង"[13]។

## III. ច្បាប់ជាធរមាន

10. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

> សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថាត្រូវបន្តការស៊ើបអង្កេតណាមួយ **ការស៊ើបអង្កេតនោះ ត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះ ឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ធ្វើការស្នើសុំនៅក្នុងរយៈ ពេលសាមសិបថ្ងៃ ឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះ** តាមមាត្រា ៧[14]។

---

១:៤៨ ល្ងាច ដោយបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់ អ.ជ.ស.ដ។ មិនមានលេខឯកសារសំណុំរឿងត្រូវបានកំណត់លើចម្លើយតបរបស់ ស.ព.អ នៅឡើយទេមកទល់ពេលនេះ។

[12] សារណារបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៨០ អមដោយឧបសម្ពន្ធសម្ងាត់ ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ *សូមមើលផងដែរ* អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១:៤៨ ល្ងាច ដោយបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់ អ.ជ.ស.ដ។ មិនមានលេខឯកសារសំណុំរឿងត្រូវបានកំណត់លើបញ្ជីរបស់ ស.ព.អ តាមវិធាន ៨០ នៅឡើយទេមកទល់ពេលនេះ។

[13] *សូមមើល* អ៊ីម៉ែលផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពី Kristin Rosella នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៥.០៩ល្ងាច។ អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចម្លងជូន។ *សូមមើលផងដែរ* អ៊ីម៉ែលរបស់ក្រឡាបញ្ជី អ.ជ.ស.ដ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១:៤៨ ល្ងាច ដោយបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់ អ.ជ.ស.ដ។ មិនមានលេខឯកសារសំណុំរឿងត្រូវបានកំណត់លើអញ្ញត្រកម្មរបស់ អោ អាន នៅឡើយទេមកទល់ពេលនេះ។

[14] គូសបញ្ជាក់បន្ថែម។

11. មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា៖

**ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះ ដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប។** ការសម្រេចសេចក្តីនេះ ត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា។ **សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗ ស្របទៅតាមការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ប្រសិនបើគ្មានមតិភាគច្រើន ដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេការស៊ើបអង្កេត ឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត**[15]។

12. មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

**សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឱ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឱ្យមានសំឡេងវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច។** សេចក្តីសំរេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាល ដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត។ **សហចៅក្រមស៊ើបអង្កេតត្រូវចាត់ការបន្តជាបន្ទាន់ ដោយអនុវត្តតាមសេចក្តីម្រេចរបស់អង្គបុរេជំនុំជម្រះនេះ។ ប្រសិនបើពុំមានមតិភាគច្រើនដូចដែលតម្រូវឱ្យមានចំពោះសេចក្តីសម្រេច ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត**[16]។

13. មាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលា ដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាម**បទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**[17]។

14. វិធាន ២១(១) ចែងថា៖

[15] គូសបញ្ជាក់បន្ថែម។

[16] គូសបញ្ជាក់បន្ថែម។

[17] គូសបញ្ជាក់បន្ថែម។

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បី**ធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព** ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង [...][18]។

15. វិធាន ៦៩(៣) ចែងថា៖

ការដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ មិនរារាំងអង្គជំនុំជម្រះសាលាដំបូង និងសហ**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការមើលសំណុំរឿង ក្នុងគោលបំណងត្រៀមរៀបចំជាមុនសម្រាប់ការជំនុំជម្រះទេ**[19]។

16. វិធាន ៧៧(១៣) ចែងថា៖

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ **សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ**របស់អង្គបុរេជំនុំជម្រះ**ត្រូវ**អនុវត្តដូចខាងក្រោម៖ [...]

ខ-ក្នុងករណីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត **ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយ**របស់សហចៅក្រមស៊ើបអង្កេត[20]។

17. វិធាន ៧៩(១) ចែងថា៖

[18] គូសបញ្ជាក់បន្ថែម។

[19] គូសបញ្ជាក់បន្ថែម។

[20] គូសបញ្ជាក់បន្ថែម។

អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹង ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

18. វិធាន ៨០(១) ចែងថា៖

សហព្រះរាជអាជ្ញា ត្រូវដាក់ជូនក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូងនូវបញ្ជីឈ្មោះសាក្សី រួមទាំងការបញ្ជាក់នូវទំនាក់ទំនងញាតិណាមួយដែលមានចែងក្នុងវិធាន ២៤(២) និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ **ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះចូលជាធរមាន។** ក្រឡាបញ្ជីត្រូវដាក់បញ្ជីនេះទៅក្នុងសំណុំរឿង និងបញ្ជូនឯកសារថតចម្លងមួយច្បាប់ទៅឲ្យភាគីដទៃទៀត ដោយគោរពទៅតាមវិធានការការពារ[21]។

19. កថាខណ្ឌ ៤១ នៃសេចក្តីពិចារណាលើកឡើងថា៖

ដោយមិគិតពីឈ្មោះរបស់វា ជាសភាស៊ើបសួរទីពីរ សភាចោទប្រកាន់ ឬអង្គបុរេជំនុំជម្រះ **អង្គជំនុំជម្រះបច្ចុប្បន្ននេះជាយុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក** [...][22]។

20. កថាខណ្ឌ ១០៩ នៃសេចក្តីពិចារណាទទួលស្គាល់គោលការណ៍ចំបងនេះថា៖

កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ចាំបាច់ត្រូវគោរពតាមលក្ខណ្ឌតម្រូវ ប្រសិទ្ធិភាព នីត្យានុកូលភាព ភាពយុត្តិធម៌ តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ក្នុងករណីនេះ លក្ខខណ្ឌតម្រូវនៃយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព មានតម្លៃសម្រាប់ការយកចិត្តទុកដាក់ជាពិសេសរបស់អង្គជំនុំជម្រះនេះ។

21. កថាខណ្ឌ ១១២ នៃសេចក្តីពិចារណាសង្កត់ធ្ងន់ថា៖

**គោលការណ៍ដែលជាមូលដ្ឋាន និងជាកត្តាកំណត់ចំពោះគោលជំហរជាក់ស្តែង មិនអាច**ត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយជាបណ្តាញ តាមរយៈការកេងចំណេញពីភាពមិនច្បាស់លាស់ដែលអាចមាននៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង

[21] គូសបញ្ជាក់បន្ថែម។

[22] គូសបញ្ជាក់បន្ថែម។

ដើម្បីធ្វើឱ្យគោលការណ៍ស្ទួលនេះក្លាយទៅជាគ្មានន័យនោះទេ។ ការសម្រេចផ្សេងពីនេះ នឹងនាំទៅដល់លទ្ធផលផ្លូវច្បាប់ ដែលមិនសមហេតុផលទាល់តែសោះ ដោយរំលោភបំពានទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា[23]។

22. កថាខណ្ឌ ១២២ នៃសេចក្តីពិចារណាក៏លើកឡើងថា៖

> **ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់ សេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ** *(jurisdictio)* **គឺជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពស់បំផុតរបស់ចៅក្រម។** ហេតុដូច្នេះ ការប្រកាសសម្រេចវិនិច្ឆ័យ និងការដោះស្រាយបញ្ហាដែលជាជម្លោះ ត្រូវមានឥទ្ធិពល និងជាកាតព្វកិច្ចផ្លូវច្បាប់ *(imperium)* ដែលខុសពីសារណារបស់ភាគី។ ចៅក្រមអាចមានកំហុសលើសេចក្តីសម្រេច ដែលអាចត្រូវបានកែតម្រូវនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែចៅក្រមមិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខខ្លួន ឬគេចចេញពីការឈានទៅសន្និដ្ឋាន ដែលសម្រេចដោយប្រសិទ្ធិភាពទៅលើបញ្ហានេះនោះទេ[24]។

23. កថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណាលើកឡើងថា៖

> ដោយផ្អែកទៅលើពាក្យពេចន៍ច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ការដែលអង្គបុរេជំនុំជម្រះ មិនអាចឈានទៅដល់សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលុប ដោយចៅក្រមយ៉ាងតិចបួនរូបនោះ មិនបានរារាំងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយនឹងសំណុំរឿង មិនឱ្យបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូង អាចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹង អោ អាន។ ស្របជាមួយបទប្បញ្ញត្តិនេះ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះ នឹងបញ្ជូនដីកាសម្រេចនេះ រួមជាមួយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសំណុំរឿងដែលនៅសេសសល់ ទៅអង្គជំនុំជម្រះសាលាដំបូង។

[23] គូសបញ្ជាក់បន្ថែម។

[24] គូសបញ្ជាក់បន្ថែម។

## IV. សេចក្តីសន្និដ្ឋាន

24. បរាជ័យរបស់ អ.ប.ជ មិនអាចរកបានសំឡេងភាគច្រើនដែលតម្រូវ ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងករណីនេះ បានបញ្ចេះឲ្យមាន "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់" ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង។ គោលជំហរស្វ័យប្រវត្តិនេះប្តឹងឲ្យ អ.ជ.ស.ដ ទទួលយករឿងក្តីនេះគិតចាប់ពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ មក។ ការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនេះ គឺជាវិបាកផ្នែករដ្ឋបាលមួយរបស់ អ.ជ.ស.ដ ដែលត្រូវបានប្តឹងឲ្យទទួលយករឿងក្តីនេះ។ យ៉ាងណាមិញ ជាងប្រាំមួយសប្តាហ៍បានកន្លងផុតតាំងពីពេលចេញសេចក្តីពិចារណា ទាំង អ.ប.ជ និងទាំងការិយាល័យរដ្ឋបាល គឺមិនបានធ្វើអ្វីឡើយលើការបញ្ជូននេះ។ ដោយហេតុថា អ.ជ.ស.ដ ត្រូវបានប្តឹងឲ្យទទួលយករឿងក្តីនេះ វិធានការកែតម្រូវទាន់ពេលវេលាដែលត្រូវធ្វើឡើងដោយ អ.ជ.ស.ដ គឺជារឿងចាំបាច់ ដើម្បីធានាកុំឲ្យមានការពន្យារពេលបន្ថែមទៀតក្នុងការចាត់ដំណើរការរឿងក្តីនេះទៅជំនុំជម្រះ។

25. ស.ព.អ យល់ថាអង្គភាពគ្រប់គ្រងតុលាការកំពុងតែរង់ចាំឲ្យ អ.ប.ជ ចាត់វិធានការរដ្ឋបាលបន្ថែម ដើម្បីបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ទៅអង្គជំនុំជម្រះនេះ។ យើងជឿថាវិធានការរដ្ឋបាលនេះអាចតម្រូវឲ្យមានការដាក់នូវទម្រង់មួយទៅ CMS ដោយគ្រាន់តែបញ្ជាក់ពីជំហរតាមសេចក្តីណែនាំដូចមានចែងក្នុងកថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណា។ ស.ព.អ ក៏យល់ផងដែរថាទោះបីជាពាក្យពេចន៍មានភាពមិនច្បាស់លាស់ក្តី សេចក្តីណែនាំមានក្នុងកថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណារបស់ អ.ប.ជ ដែលថា "ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ នឹងបញ្ជូនសេចក្តីពិចារណានេះ... ដីកាបញ្ជូនរឿងទៅជំនុំជម្រះ... និងសំណុំរឿងដែលនៅសេសសល់ទៅអង្គជំនុំជម្រះសាលាដំបូង"នោះ គឺជាសិទ្ធិអំណាចគ្រប់គ្រាន់សម្រាប់ CMS ត្រូវចាត់វិធានការនេះ។

26. ស.ព.អ សូមផ្តល់អនុសាសន៍ឲ្យមានវិធានការបន្ទាន់របស់ អ.ប.ជ ដើម្បីទទួលបានដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងសំណុំរឿងដែលនៅសេសសល់ ដោយសារមានមូលហេតុជាច្រើនដែលអនុញ្ញាត។ ទីមួយ គឺដើម្បីធានាថា តុលាការមិនមានហានិភ័យក្នុងការកំណត់អាទិភាពអំពីសារធាតុ និងបច្ចេកទេសនៅលើគោលការណ៍ស្នូល។ ដូច អង្គជំនុំជម្រះបានសង្កត់ធ្ងន់នៅក្នុងសេចក្តីពិចារណារបស់ខ្លួនថា "គោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ មិនអាចត្រូវបានទាត់ចោល ឬដកហូតឥទ្ធិពល និងទម្ងន់ពេញទាំងស្រុងរបស់វា" ដោយសារ "ការរៀបចំការបកស្រាយជាបណ្តាញ" ដើម្បី "ធ្វើឲ្យគោលការណ៍ស្នូលនេះក្លាយទៅជាឥតន័យនោះទេ។ ការសន្និដ្ឋានផ្សេងពីនេះនឹងនាំទៅ

ដល់លទ្ធផលផ្លូវច្បាប់ដែលមិនសមហេតុផលទាល់តែសោះ ដោយរំលោភទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា”[25]។

27. ទីពីរ វិធានការបន្ទាន់ គឺជាការតម្រូវដើម្បីរារាំងដល់ការពន្យារពេលបន្ថែមទៀត មិនដូច្នោះទេការដែលគ្មានសកម្មភាពជាបន្ត នឹងធ្វើឲ្យខូចដល់ភាពប្រាកដប្រជា និងតម្លាភាពផ្លូវច្បាប់ដែលត្រូវបានផ្តល់ដោយសេចក្តីសម្រេចដែលគ្មានសម្លេងគាំទ្រគ្រប់គ្រាន់ និងដែលបានតម្រូវតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង។ ការពន្យារពេលដែលមានស្រាប់ បង្កើតឲ្យមានភាពមិនប្រាកដប្រជា និងកង្វះនូវតម្លាភាពអំពីការរីកចម្រើននៃរឿងក្តីនេះ។ បច្ចុប្បន្ន វាមិនច្បាស់ទាំងចំពោះជនជាប់ចោទ គូភាគីប្រជាពលរដ្ឋកម្ពុជា និងសហគមន៍អន្តរជាតិ ថាតើ ជនជនជាប់ចោទរូបនេះ នឹងត្រូវបាននាំខ្លួនមកកាន់ការជំនុំជម្រះដែរឬអត់ ឬមួយក៏ទុកឲ្យបទចោទធ្ងន់ធ្ងរបច្ចុប្បន្ននេះស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជាខាងផ្លូវច្បាប់ជារៀងរហូតទៅ។ ចំពោះភាពមិនប្រាកដប្រជាដូច្នេះ គឺផ្ទុយទៅនឹងការធ្វើឲ្យគោលជំហរស្វ័យប្រវត្តិដំណើរការបានដោយប្រសិទ្ធិភាព ដែលបញ្ចៀសខបសគ្គផ្លូវច្បាប់បច្ចុប្បន្ន។

28. ទីបី ពេលនេះតម្រូវឲ្យមានវិធានហើយ ដើម្បីធានាថា ការជំនុំជម្រះដំណើរការដោយឆាប់រហ័សស្របតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ សំខាន់បំផុត អ.ជ.ស.ដ សន្និដ្ឋានថា ពេលនេះតម្រូវឲ្យមានវិធានការឆាប់រហ័សពី អ.ជ.ស.ដ ដើម្បីដោះស្រាយភាពជាប់គាំងបច្ចុប្បន្ន ដោយហេតុថា បរាជ័យនៃភាពរីកចម្រើនចំពោះរឿងក្តីនេះទៅកាន់ការជំនុំជម្រះ នឹងបង្កើតបានជាការច្រានចោលដោយការសន្មតចំពោះរឿងក្តីនេះ”[26]។ ជាការបន្ថែម ការខកខានក្នុងការទទួលបាននូវលទ្ធភាពចូលពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនិងសំណុំរឿងដែលនៅសេសសល់នេះ នឹងរារាំងដល់អ.ជ.ស.ដ ក្នុងការអនុវត្ត“*ភារកិច្ចតាមផ្លូវតុលាការរបស់ខ្លួន ក្នុងការប្រកាសដោយផ្អែកទៅលើច្បាប់ នូវសេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ... គឺចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់របស់ចៅក្រម*”[27]។ ក្នុងករណីនេះ បញ្ហាដែលបានជំទាស់ដោយ អោ អាន គឺបញ្ហាយុត្តាធិការរបស់ អ.ជ.ស.ដ ទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

---

[25] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា, កថាខណ្ឌ ១១២។

[26] សំណុំរឿង ០០៤/២-ឯកសារ **A117/2/2** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មតលើសំណើ លើកទីបួនរបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤, កថាខណ្ឌ ១១: (“ទ្រឹស្តីនៃការបដិសេធ តាមការសន្មត[...] អង្គជម្រះបុរេជំនុំជម្រះបានអនុវត្តសម្រាប់កាលៈទេសៈពិសេសទាំងឡាយ ដែលការិយាល័យសហចៅក្រម ស៊ើបអង្កេតមិនមានសកម្មភាព ឬការពន្យារពេលវេលាក្នុងការបំពេញកិច្ច អាចបណ្តាលឲ្យមានព្យសនកម្ម”)។

[27] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណា, កថាខណ្ឌ ១២២។

## V. សេចក្តីសន្និដ្ឋានចុងក្រោយ

29. ស.ព.អ សន្និដ្ឋានថា ភាពជាប់គាំងផ្នែករដ្ឋបាលចុះប្បន្ន តម្រូវឲ្យមានសកម្មភាពបន្ទាន់ដោយ អ.ជ.ស.ដ ដើម្បីធានាដល់ការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យបានឆាប់ ប្រសិនបើការបញ្ជូនជាផ្លូវការដូច្នេះតម្រូវ ព្រមទាំងសំណុំរឿងដែលនៅសេសសល់ទៅនឹងដីកានេះផង ដើម្បីលើកកម្ពស់ភាពប្រាកដប្រជា និងតម្លាភាពផ្លូវច្បាប់ដែលត្រូវបានផ្តល់ដោយសេចក្តីសម្រេចដែលគ្មានសំឡេងគាំទ្រគ្រប់គ្រាន់ និងដែលបានតម្រូវតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង។ មានការសន្និដ្ឋានថា ផលប៉ះពាល់បណ្តាលមកពីកង្វះនូវសិទ្ធិចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ដោយ អ.ជ.ស.ដ គឺជាការរំលោភលើសេចក្តីសម្រេចស្វ័យប្រវត្តិដែលមានលក្ខណៈចាប់បង្ខំ ជាការបដិសេធនូវសិទ្ធិរបស់ជនជនចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័ស ជាការបដិសេធនូវសិទ្ធិរបស់ជនរងគ្រោះ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានយុត្តិធម៌ ជាការធ្វើឲ្យខូចដល់សុចរិតភាពនៃដំណើរការរបស់ អ.វ.ត.ក និងជាការបង្អាក់ដល់កិច្ចការគ្រប់គ្រងរដ្ឋបាលតុលាការដ៏ត្រឹមត្រូវក្នុងរឿងក្តីនេះ។

## VI. ឧបាស្រ័យដែលស្នើឡើង

30. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ៖

(ក) ស្នើឲ្យ អ.ប.ជ ចាត់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវសំណុំរឿងដែលនៅសេសសល់នៃសំណុំរឿង០០៤/២ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រសិនបើការបញ្ជូនជាផ្លូវការដូច្នេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈតម្រូវ ទៅ អ.ជ.ស.ដ ឬបើតាមជម្រើសផ្សេង;

(ខ) ក្នុងករណីដែល អ.ប.ជ មិនបានចាត់វិធានការចាំបាច់ទាំងអស់ដើម្បីផ្តល់ឲ្យ អ.ជ.ស.ដ នូវសិទ្ធិចូលពិនិត្យមើលសំណុំរឿងដែលនៅសេសសល់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះឲ្យបានឆាប់តាមដែលអាចធ្វើបានបន្ទាប់ពីបានទទួលសំណើរបស់ អ.ជ.ស.ដ សូមបង្គាប់ទៅការិយាល័យរដ្ឋបាលឲ្យផ្តល់ជាបន្ទាន់ដល់ អ.ជ.ស.ដ នូវសិទ្ធិចូលពិនិត្យមើលសំណុំរឿងដែលនៅសេសសល់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ;

(គ) ផ្តល់ឲ្យ CMS នូវលេខសំណុំរឿងសម្រាប់រឿងក្តីនេះ ហើយនឹង

(ឃ) កំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ | លោកស្រី Brenda J. HOLLIS សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |